ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៩០......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃសេវាកម្មធនាគារពាណិជ្ជ សម្រាប់ប្រតិបត្តិការចំណូល-ចំណាយថវិកា នៅខេត្តគោលដៅចំនួន ៩

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងឋានៈចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

**សម្រេច**

**ប្រការ១.-** ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃសេវាកម្មធនាគារពាណិជ្ជសម្រាប់ប្រតិបត្តិការចំណូល-ចំណាយថវិកា នៅខេត្តគោលដៅចំនួន៩ គឺ ខេត្តកំពង់ចាម ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តកោះកុង និង ខេត្តឧត្តរមានជ័យ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម ជូ គីមឡេង | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម ឆែន ឃេន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន រតនាគារជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម ហ៊ីវ សុវណ្ណ | អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៤-ឯកឧត្តម វង្ស ប៊ុនឥន្ទ្រាវុធ | អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៥-លោក មាស ប៊ុនធុន | អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៦-លោក អ៊ិន សុម៉េធ | ប្រធានអង្គភាពគ្រប់គ្រងសាច់ប្រាក់ | សមាជិក |
| ៧-ប្រធាននាយកដ្ឋានទាំងអស់នៃអគ្គនាយកដ្ឋានរតនាគារជាតិ | | សមាជិក |
| ៨-លោក ខួន វិច្ឆ៊ា | ប្រធាននាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន និងសរុបស្ថិតិ នៃអគ្គនាយកដ្ឋានរតនាគារជាតិ | លេខាធិការ |

**ប្រការ២-** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ នាយកខុទ្ទកាល័យ គ្រប់ប្រធាននាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ២០១០

**កន្លែងទទួល:**

-ដូចប្រការ ២

-ឯកសារ-កាលប្បវត្តិ

គាត ឈន់